ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១២៦៨ ធទឧ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការបច្ចេកទេស គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងមេទឹក

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ ស្តីពី ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញលិខិតលេខ ១៣៥១ សជណ.ឧស ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ០៦៧ សសរ.ធទឧ ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៧ របស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

## សម្រេច

**ប្រការ ១.-**

បង្កើតអនុគណៈកម្មការបច្ចេកទេសគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងមេទឹក មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ម៉ិន ហ៊ាន** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២- ឯកឧត្តម | **តែ ណាវុធ** | អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | អនុប្រធាន |
| ៣- ឯកឧត្តម | **ឡុង សារាវុធ** | អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៤- ឯកឧត្តម | **គឹម ណុង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ៥- លោក | **ម៉ៅ ហាក់** | អគ្គនាយករងកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦- លោក | **ឆេង ផែន** | អនុប្រធានរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- បណ្ឌិត | **កែវ អូម៉ាលីស្ស** | អនុប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- លោក | **ជា ណារិន** | ប្រធាននាយកដ្ឋានវារីអគ្គិសនី នៃក្រសួងរ៉ែ និងថាមពល | សមាជិក |

*អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥)២៣ ២១៦ ៦៧០
#364 Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670

៩- លោក **តាំង សុចិត្រា** ប្រធាននាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សមាជិក

១០- លោក **សុខ ម៉ា** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍តាមព្រំដែន នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សមាជិក

១១- លោក **យ៉ង់ តិរមៀ** អនុប្រធាននាយកដ្ឋានអភិរក្សតំបន់ដីគោកខាងត្បូង បឹងទន្លេសាប នៃក្រសួងបរិស្ថាន សមាជិក

១២- លោក **ហេង ហុង** អនុប្រធាននាយកដ្ឋានជីវភាពសហគមន៍ នៃក្រសួងបរិស្ថាន សមាជិក

១៣- លោក **នង សារ៉េត** អនុប្រធាននាយកដ្ឋានវារីអគ្គិសនី នៃក្រសួងរ៉ែ និងថាមពល សមាជិក

១៤- លោក **ជី ច័ន្ទរស្មី** អនុប្រធាននាយកដ្ឋានវារីអគ្គិសនី នៃក្រសួងរ៉ែ និងថាមពល សមាជិក

១៥- លោក **អៀន សាម៉ាន** អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកោះកុង សមាជិក

១៦- លោក **ចាន់ ភក្តដា** អនុប្រធានការិយាល័យគ្រប់គ្រងច្រាំងទន្លេ នៃក្រសួងធនធានទឹក និងឧតុនិយម សមាជិក

១៧- លោក **ឡឹក វណ្ណសុបញ្ញា** មន្ត្រី នៃក្រសួងរ៉ែ និងថាមពល សមាជិក

**ប្រការ ២ .-**

អនុគណៈកម្មការបច្ចេកទេសគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងមេទឹក មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ចុះធ្វើការសិក្សា ស្រាវជ្រាវដល់ទីតាំងគម្រោងជាក់ស្តែង ដើម្បីប្រមូលទិន្នន័យបឋមផ្នែកបច្ចេកទេស ផលប៉ះពាល់បរិស្ថាន-សង្គម ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី
- ធ្វើការបង្ហាញលទ្ធភាពជម្រើសនៃគម្រោង និងវិភាគអំពីសក្តានុពលសេដ្ឋកិច្ចនៃគម្រោង
- សិក្សាលើទិដ្ឋភាពច្បាប់ ពាក់ព័ន្ធនឹងការបង្វែរទឹកឆ្លងកាត់ព្រំដែនចេញពីព្រះរាជាណាចក្រកម្ពុជា
- ធ្វើរបាយការណ៍ជូនប្រធានគណៈកម្មការគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងមេទឹក
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងមេទឹក ប្រគល់ជូន ។

**ប្រការ ៣ .-**

ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧*

**រដ្ឋមន្ត្រី**

**លឹម គានហោ**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៣

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ